# អង្គុលិមាលឧទានគាថា



*វេលានោះ អង្គុលិមាលមានអាយុ ទៅនៅក្នុងទីរហោស្ថានសម្ងំតែម្នាក់ឯង បានប្រទះនូវវិមុត្តិសុខ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា*

**យោ បុព្វេ បមជ្ជិត្វា, បច្ឆា សោ នប្បមជ្ជតិ;**
**សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។**

*បុគ្គលណា ធ្វេសប្រហែសក្នុងកាលមុន ដល់កាលជាខាងក្រោយមក បុគ្គលនោះមិនធ្វេសប្រហែសវិញ បុគ្គលនោះ ឈ្មោះថាញាំងលោក នេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។*

**យស្ស ចាបំ កតំ កម្មំ, កុសលេន បិធីយតិ;**

**សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។**

*បាបកម្មដែលបុគ្គលណាធ្វើហើយ តែបុគ្គលនោះត្រឡប់ជាបិទបាន គឺមិនទទួលផលកម្មវិញ ដោយសារកុសលគឺមគ្គ បុគ្គលនោះឈ្មោះថា ញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។*

**យោ ហវេ ទហរោ ភិក្ខុ, យុញ្ជតិ ពុទ្ធសាសនេ;**
**សោមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា។**

*ភិក្ខុណា កំឡោះនៅឡើយ ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯង*

*ឈ្មោះថាញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតស្រឡះ*

*ចាកពពក។*

**ទិសា ហិ មេ ធម្មកថំ សុណន្តុ,**
**ទិសា ហិ មេ យុញ្ជន្តុ ពុទ្ធសាសនេ;**
**ទិសា ហិ មេ តេ មនុជា ភជន្តុ,**
**យេ ធម្មមេវាទបយន្តិ សន្តោ។**

*សូមពួកមនុស្សជាសត្រូវ ស្តាប់ធម្មកថារបស់ខ្ញុំ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ប្រកបព្យាយាមក្នុងពុទ្ធសាសនា ពួកសប្បុរសណា តែងដឹកនាំមនុស្សឲ្យរៀនធម៌ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ សេពគប់ពួកសប្បុរសទាំងនោះចុះ។*

**ទិសា ហិ មេ ខន្តិវាទានំ, អវិរោធប្បសំសីនំ;**
**សុណន្តុ ធម្មំ កាលេន, តញ្ច អនុវិធីយន្តុ។**

សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ស្តាប់ធម៌ជាទីផូរផង់ គឺខន្តិ ទាំងជាទីសរសើរនូវការមិនខឹង គឺមេត្តា តាមកាលដ៏សមគួរផង សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ បំពេញនូវធម៌នោះផង ។

**ន ហិ ជាតុ សោ មមំ ហឹំសេ, អញ្ញំ វា បន កិញ្ចិ នំ;**
**បប្បុយ្យ បរមំ សន្តឹ, រក្ខេយ្យ តសថាវរេ។**

មនុស្សណាជាសត្រូវនឹងខ្ញុំ សូមសត្រូវនោះកុំបៀតបៀនខ្ញុំ ទាំងកុំបៀតបៀនបុគ្គលដទៃណាមួយឡើយ សូមឲ្យដល់នូវសេចក្តីសុខគឺព្រះនិព្វាន ចូររក្សានូវមនុស្សដែលប្រកបដោយតណ្ហា និងមនុស្សដែលមិនមានតណ្ហា ។

**ឧទកញ្ហិ នយន្តិ នេត្តិកា, ឧសុការា នមយន្តិ តេជនំ;**
**ទារុំ នមយន្តិ តច្ឆកា, អត្តានំ ទមយន្តិ បណ្ឌិតា។**

ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹក (តាមប្រឡាយទឹក) ពួកអ្នកធ្វើកូនសរ រមែងពត់កូនសរ ពួកអ្នកចាំងឈើរមែងចាំងឈើ អ្នកប្រាជ្ញទាំងឡាយរមែងទូន្មានខ្លួនបានដូច្នោះដែរ ។

**ទណ្ឌេនេកេ ទមយន្តិ, អង្កុសេហិ កសាហិ ច;**
**អទណ្ឌេន អសត្ថេន, អហំ ទន្តោម្ហិ តាទិនា។**

ពួកមនុស្សខ្លះទូន្មានដោយដំបង ដោយកង្វេរ ដោយរំពាត់ ចំណែកខ្ញុំជាអ្នកមានអាជ្ញាដែលព្រះមានបុណ្យ ជាតាទិបុគ្គល មិនបានយកដំបង ឬគ្រឿងសស្ត្រាវុធ (មកទូន្មានខ្ញុំទេ)។

**អហឹំសកោតិ មេ នាមំ, ហឹំសកស្ស បុរេ សតោ;**
**អជ្ជាហំ សច្ចនាមោម្ហិ, ន នំ ហឹំសាមិ កិញ្ចិ នំ។**

កាលដើមខ្ញុំឈ្មោះថា អហឹសកកុមារ (ជាអ្នកមិនបៀតបៀនគេ) តែជាអ្នកបៀតបៀនគេ ដល់មកថ្ងៃនេះ ខ្ញុំមានឈ្មោះទៀងទាត់ គឺសមតាមឈ្មោះដើមខ្ញុំហើយ ព្រោះខ្ញុំមិនបៀតបៀនអ្នកណាមួយទៀតទេ ។

**ចោរោ អហំ បុរេ អាសឹ, អង្គុលិមាលោតិ វិស្សុតោ;**
**វុយ្ហមានោ មហោឃេន, ពុទ្ធំ សរណមាគមំ។**

*កាលពីដើមខ្ញុំជាចោរ មាននាមប្រាកដថា អង្គុលិមាល ដែលជំនន់ធំបន្សាត់ទៅ (តែឥឡូវនេះ) ខ្ញុំបានដល់នូវព្រះពុទ្ធជាទីពឹងហើយ ។*

**លោហិតបាណិ បុរេ អាសឹ, អង្គុលិមាលោតិ វិស្សុតោ;**
**សរណគមនំ បស្ស, ភវនេត្តិ សមូហតា។**

*កាលពីដើម ខ្ញុំមានដៃប្រឡាក់ឈាម មាននាមប្រាកដថាអង្គុលិមាល (តែឥឡូវនេះ) សរណគមន៍ខ្ញុំបានដល់ហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានគាស់រំលើងចោលហើយ ។*

**តាទិសំ កម្មំ កត្វាន, ពហុំ ទុគ្គតិគាមិនំ;**
**ផុដ្ឋោ កម្មវិបាកេន, អណណោ ភុញ្ជាមិ ភោជនំ។**

*ខ្ញុំបានធ្វើអំពើ ដែលគួរទៅកាន់ទុគ្គតិដូច្នោះច្រើនពិតមែន តែកម្មវិបាក គឺមគ្គចេតនាបានមកអប់រំ (ក្នុងសន្តានខ្ញុំហើយ) ខ្ញុំជាអ្នកលែងចំពាក់បំណុលគឺកិលេស បរិភោគភោជន ។*

**បមាទមនុយុញ្ជន្តិ, ពាលា ទុម្មេធិនោ ជនា;**
**អប្បមាទញ្ច មេធាវី, ធនំ សេដ្ឋំវ រក្ខតិ។**

*ពួកជនពាលឥតប្រាជ្ញា តែងប្រកបសេចក្ដីប្រមាទ ឯអ្នកប្រាជ្ញតែងរក្សាសេចក្ដីមិនប្រមាទទុក ដូចរក្សាទ្រព្យដ៏ថ្លៃថ្លា ។*

**មា បមាទមនុយុញ្ជេថ, មា កាមរតិ សន្ថវំ;**
**អប្បមត្តោ ហិ ឈាយន្តោ, បប្បោតិ វិបុលំ សុខំ។**

*សូមអ្នកទាំងឡាយ កុំប្រកបសេចក្ដីប្រមាទឡើយ កុំប្រកបសេចក្ដីត្រេកអរ នឹងការមូលមិត្រក្នុងកាមឡើយ ព្រោះថាបុគ្គលអ្នកមិនប្រហែសធ្វេស ខំដុតបំផ្លាញ (នូវកិលេស) រមែងបានដល់នូវសេចក្ដីសុខដ៏ទូលាយ។*

**ស្វាគតំ នាបគតំ, នយិទំ ទុម្មន្តិតំ មម;**
**សំវិភត្តេសុ ធម្មេសុ, យំ សេដ្ឋំ តទុបាគមិំ។**

*ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ បណ្ដាធម៌ទាំងឡាយ ដែលព្រះអង្គចែករំលែកល្អហើយ ព្រះនិព្វានណាជាគុណជាតដ៏ប្រសើរ ខ្ញុំបានដល់នូវព្រះនិព្វាននោះហើយ។*

**ស្វាគតំ នាបគតំ, នយិទំ ទុម្មន្តិតំ មម;**
**តិស្សោ វិជ្ជា អនុប្បត្តា, កតំ ពុទ្ធស្ស សាសនំ។**

*ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ វិជ្ជា ៣ ប្រការ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំបានធ្វើតាមហើយ ។*

*(សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក រាជវគ្គ អង្គុលិមាលសូត្រ)*

*ដោយស.ជ.វ.ថ.*